**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Nov-2011, 14:13
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា
# លើបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រ៊ឹម, ប្រធាន
ចៅក្រម Motoo NOGUCHI
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម C. N. JAYASINGHE
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**
ជនជាប់ចោទ:
អៀង ធីរិទ្ធ

មេធាវីការពារក្តីជនជាប់ចោទ:
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC

**សហមេធាវីនាំមុខតំណាងដើមបណ្តឹង**
**រដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

# I. សេចក្តីផ្តើម និង ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចបំបែកបទចោទប្រកាន់លើជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០២, ប្រកាសផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងលើរូបគាត់ និងបង្គាប់ឲ្យដោះលែងគាត់ពីមន្ទីរឃុំឃាំង នៅក្រោមលក្ខខណ្ឌមួយដែលគាត់ត្រូវជូនដំណឹងដល់អង្គជំនុំជម្រះ មុននឹងប្តូរអាសយដ្ឋានទៅកន្លែងផ្សេង[1]។

២. នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់*បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ* (“បណ្តឹងសាទុក្ខ”)[2] ហើយស្របគ្នានោះ បានដាក់*សំណើសុំផ្អាកការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ*[3]។ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១១ ដោយអនុលោមតាមវិធាន ៨២.៦[4] ប្រធានអង្គជំនុំជម្រះតុលាការកំពូល (“អង្គជំនុំជម្រះ”) បានបង្គាប់ឲ្យផ្អាកការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ រហូតដល់អង្គជំនុំជម្រះចេញសាលដីកាលើបណ្តឹងសាទុក្ខនេះ[5]។

៣. នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះក៏បានយល់ព្រមជាផ្នែកផងដែរ លើសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំដាក់សេចក្តីសន្និដ្ឋានបន្ថែម ដោយអនុញ្ញាតឲ្យមួយ(០១)ថ្ងៃ សម្រាប់គោលបំណងនេះ។ សេចក្តីសន្និដ្ឋាននេះត្រូវដាក់នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ដោយស្ថិតនៅក្នុងពេលវេលាកម្រិតឲ្យដោយអង្គជំនុំជម្រះ។ គោលបំណងរបស់ខ្លួន គឺគ្រាន់តែ លើកឡើងនូវភ័ស្តុតាង និងសម្អាងហេតុគាំទ្រនានាដែល *មិនអាចនឹងលើកឡើងបានគ្រប់គ្រាន់* នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន ដោយសាររយៈពេលដែលបានផ្តល់ឲ្យនៅក្នុងវិធានខ្លីពេក។ សេចក្តីសន្និដ្ឋាននេះ គួរតែមានខ្លឹមសារស្របគ្នាជាមួយនឹងបណ្តឹងសាទុក្ខ។

---

[1] **E138** សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ, ១៧ វិច្ឆិកា ២០១១ (“សេចក្តីសម្រេចដែលរងការជំទាស់”) ។

[2] **E138/1/1** បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ១៨ វិច្ឆិកា ២០១១ ។

[3] **E138/1/2** សំណើរបស់សហព្រះរាជអាជ្ញា សុំផ្អាកការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ១៨ វិច្ឆិកា ២០១១ ។

[4] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធកម្មលើកទី៨) ដែលបានពិនិត្យសារឡើងវិញ នៅថ្ងៃទី៣ សីហា ២០១១ (“វិធាន”) ។

[5] **E138/1/3** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់សេចក្តីសន្និដ្ឋានបន្ថែម និងសេចក្តីណែនាំពាក់ព័ន្ធនឹងការដាក់បណ្តឹងសាទុក្ខ, ២១ វិច្ឆិកា ២០១១ ត្រង់ទំព័រទី ២ ។

## II. សេចក្តីសន្និដ្ឋានបន្ថែម អំពីការបញ្ចប់កិច្ចដំណើរការនីតិវិធីដ៏មានប្រសិទ្ធភាព ជាកំហុសខាងអង្គច្បាប់

៩. នៅក្នុងកថាខណ្ឌទី ៥ នៃបណ្តឹងសាទុក្ខ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ ត្រូវបានបញ្ចប់ដោយប្រសិទ្ធភាពរួចទៅហើយ ដោយហេតុថា សហព្រះរាជអាជ្ញា ប្រកាន់ជំហរនឹងមិនស្នើសុំឱ្យមានការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីនោះឡើងវិញបានទេ។ សេចក្តីសម្រេចដែលរងការជំទាស់ បានជ្រើសរើសយកភាសាដាច់ខាតមួយ ដោយតម្រូវថា "... សហព្រះរាជអាជ្ញា ត្រូវ*បង្កើត* យន្តការត្រួតពិនិត្យស្ថានភាពសុខភាពជនជាប់ចោទជាប្រចាំ"[6]។ ខណៈដែលកិច្ចដំណើរការនីតិវិធីត្រូវបានផ្អាក ប៉ុន្តែមិនត្រូវបានបញ្ចប់នោះទេ ដូច្នេះ សមត្ថកិច្ចក្នុងការដាក់ឱ្យអនុវត្ត និងត្រួតពិនិត្យលក្ខខណ្ឌនានាដែលកម្រិតលើសេរីភាពរបស់ជនចាប់ចោទ ត្រូវស្ថិតនៅលើអង្គជំនុំជម្រះសាលាដំបូងតែម្នាក់ឯង ដោយហេតុថា អង្គជំនុំជម្រះនេះមានអំណាចតាមផ្លូវតុលាការលើបណ្តឹងសាទុក្ខ។ សមត្ថកិច្ចនេះមាននៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងដែលគេបានបង្កើតឡើងយ៉ាងត្រឹមត្រូវ ទៅលើជនជាប់ចោទនៅពេលដែល "បានទទួលបណ្តឹងដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ"[7]។ ប្រព័ន្ធច្បាប់នានានៅក្នុងប្រពៃណីច្បាប់ស៊ីវិល រួមទាំង ប្រទេសកម្ពុជា និងបារាំងផង បានទទួលស្គាល់ថា តុលាការត្រូវទទួល*ទាំងបណ្តឹងពីវត្ថុ និងទាំងបណ្តឹងពីបុគ្គល* (both *in rem* and *in personam*) - គឺតុលាការមានយុត្តាធិការលើគ្រប់អង្គហេតុទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយ ហើយអនុវត្តយុត្តាធិការនេះទៅលើបុគ្គលទាំងឡាយណា ដែលមាននៅក្នុងនោះតែប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ គេក៏ត្រូវតែអនុវត្តយុត្តាធិការនេះទៅលើបុគ្គលទាំងនោះផងដែរ[8]។

---

[6] **E138** សេចក្តីសម្រេចដែលរងការជំទាស់, (ផ្នែកសម្រេចសេចក្តី), កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់ទំព័រទី ៣០ [សង្កត់ន័យបន្ថែមដោយ*អក្សរទ្រេត*] ។

[7] វិធាន ៧៩.១ ។

[8] Jean Pradel, *Procédure pénale* (បោះពុម្ពលើកទី ១៣), ss. 837, 846 ។

៥. ខណៈដែលកិច្ចដំណើរការនីតិវិធីត្រូវបានផ្អាកនៅដំណាក់កាលសវនាការ សហព្រះរាជអាជ្ញានៅតែជាភាគីតទល់គ្នាមួយនៅក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទដដែល[9]។ ដូច្នេះ វាគឺជាការមួយដែលមិនមានលក្ខណៈសមស្របទេ ដែលសម្រេចឲ្យសហព្រះរាជអាជ្ញាអនុវត្តនូវអំណាច *តាមគំនិតរបស់ខ្លួនផ្ទាល់* ណាមួយ (*propio motu*) ដែលទាក់ទងទៅនឹងការកម្រិតសេរីភាពរបស់គាត់។ អនុលោមតាមវិធាន៥១ វិធានការបង្ខំមួយគត់របស់សហព្រះរាជអាជ្ញា គឺអំណាចបង្គាប់ឲ្យនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនជនសង្ស័យដើម្បីស៊ើបសួរ។ ការឃាត់ខ្លួនបែបដូច្នេះត្រូវបានកម្រិតត្រឹម ៧២ ម៉ោង និងត្រូវស្ថិតនៅក្រោមកិច្ចការពារជាច្រើនលើសិទ្ធិរបស់ជនជាប់ចោទផងដែរ។ មិនមានមូលដ្ឋានផ្សេងណាមួយដែលគេអាចរកឃើញ នៅក្នុងអត្ថបទច្បាប់របស់ អវតក ដើម្បីអនុញ្ញាតឲ្យ និងនិយ័តកម្មតាមផ្លូវច្បាប់នូវអំណាច ដូចដែលត្រូវបានផ្តល់ឲ្យសហព្រះរាជអាជ្ញា នៅក្នុងដីកាសម្រេចដែលរងការជំទាស់នេះឡើយ។

៦. ការដែលអង្គជំនុំជម្រះសាលាដំបូង ធ្វើការផ្ទេរនូវទិដ្ឋភាពណាមួយនៃសមត្ថកិច្ចរបស់ខ្លួនលើជនជាប់ចោទ ឲ្យទៅសហព្រះរាជអាជ្ញា គឺមានបញ្ហាទាំងជាមួយនឹងការធានានូវភាពដាច់ដោយឡែកពីគ្នារវាងអំណាចការចោទប្រកាន់ និងអំណាចជំនុំជម្រះ នៅក្រោមវិធាន២១(១)(ក) និងលក្ខខណ្ឌត្រួតពិនិត្យមានប្រសិទ្ធភាព ដោយ "អំណាចតុលាការ" មានសមត្ថកិច្ច នៅក្រោមវិធាន ២១ (២)។ ពិតមែនហើយ ប្រព័ន្ធណាមួយក៏ដោយដែលឃ្លាំមើលសុខភាពរបស់ជនជាប់ចោទ ដើម្បីចាប់ផ្តើមជាថ្មីឡើងវិញនូវកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ត្រូវតែពឹងផ្អែកលើការអនុវត្តវិធានការបង្ខំនានា ដែលបង្គាប់ឲ្យជនជាប់ចោទដាក់របាយការណ៍វេជ្ជសាស្ត្រ ឬមួយក៏របាយការណ៍វេជ្ជសាស្ត្រនោះគ្មានប្រសិទ្ធភាពទាំងស្រុង។ ការណ៍នេះបានពង្រឹកសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដែលថាអង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់យ៉ាងមានប្រសិទ្ធភាព លើកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ ហើយថាដីកាសម្រេចដែលរងការជំទាស់នោះ គឺមិនមានសុពលភាពទេ ដោយសារកំហុសខាងអង្គច្បាប់នេះ។

---

[9] *ដដែលដូចមុន,* s. 164, កន្លែងដែលម្ចាស់អត្ថបទបានកត់សម្គាល់៖ "…le parquet…est donc *partie* au **procès** pénal, non juge" និងបញ្ជាក់ពីវិសាលភាពនៃអំណាចរបស់អយ្យការ ។

## III. សេចក្តីសន្និដ្ឋានបន្ថែមលើវិសាលភាពនៃ សមត្ថកិច្ច ដើម្បីកម្រិតសេរីភាពរបស់ជនជាប់ចោទ

### *(i) ដោយសារកំហុសខាងអង្គច្បាប់ ធ្វើឲ្យសេចក្តីសម្រេចដែលរងការជំទាស់នេះ អស់សុពលភាព*

៧. ដោយយោងទៅកថាខណ្ឌទី ៧ ដល់ ១៤ នៃបណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូងបានដាក់សេចក្តីសម្រេចរបស់ខ្លួនដែលអនុញ្ញាតឲ្យមានការដោះលែងជនជាប់ចោទដោយឥតលក្ខខណ្ឌ ឈរលើមូលដ្ឋានដែលស្តីពីគោលការណ៍នៃការសន្មតតាមច្បាប់ព្រហ្មទណ្ឌ និងការបកស្រាយច្បាប់ព្រហ្មទណ្ឌ ដោយផ្តល់ប្រយោជន៍ឲ្យជនជាប់ចោទ[10], មូលដ្ឋានស្តីពី "គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់សិទ្ធិមនុស្ស"[11] និងមូលដ្ឋានស្តីពីសិទ្ធិក្នុងការមានសេរីភាព ក្រោមមាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)។ ទាំងអស់នេះសហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ច្បាស់លាស់រួចមកហើយថា "វិធានផ្ទៃក្នុង ត្រូវតែបានបកស្រាយដោយធានានូវផលប្រយោជន៍ដល់ជនជាប់ចោទជានិច្ច"[12]។

៨. ដោយស្របគ្នាទៅនឹងមាត្រា៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សិទ្ធិក្នុងការមានសេរីភាពរបស់បុគ្គលដែលបានជាប់ចោទពីបទឧក្រិដ្ឋអន្តរជាតិធំៗ ហើយដែលដំណើរការនីតិវិធីប្រឆាំងនឹងបុគ្គលនោះត្រូវបានផ្អាក គឺមិនមានលក្ខណៈដាច់ខាតនោះទេ។ វិធីសាស្ត្រសមស្រប គឺត្រូវបានឆ្លុះបញ្ចាំងយ៉ាងប្រសើរបំផុត នៅក្នុងវិធាននីតិវិធីដែលបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ និងការអនុវត្តរបស់តុលាការពិសេស និងតុលាការព្រហ្មទណ្ឌនានាបែបអន្តរជាតិ។ យុត្តិសាស្ត្រនេះបានបង្កើតយ៉ាងច្បាស់លាស់នូវការផ្អាកកិច្ចដំណើរការនីតិវិធីមួយ ជាបណ្តោះអាសន្នប្រឆាំងនឹងជនជាប់ចោទ អាចត្រូវបានអនុញ្ញាតឲ្យមាននៅក្នុងករណីដែលមានជម្ងឺធ្ងន់ធ្ងរបំផុត ក៏ប៉ុន្តែការដោះលែងដោយឥតលក្ខខណ្ឌ ការដកការចោទប្រកាន់ ឬការបញ្ចប់ គឺជាការលើកលែង មិនមែនជាបទដ្ឋាននោះទេ សូម្បីតែមិនមានលទ្ធភាពនៅក្នុងការធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌផ្នែកវេជ្ជសាស្ត្រជាមូលដ្ឋានក៏ដោយ។

---

[10] **E138** សេចក្តីសម្រេចដែលរងការជំទាស់, *ដដែលដូចមុន* ត្រង់កថាខណ្ឌទី ៨០ ។

[11] **E138** សេចក្តីសម្រេចដែលរងការជំទាស់, *ដដែលដូចមុន* ត្រង់កថាខណ្ឌទី ៧៩ ។

[12] **E50/3/1/4** *ដដែលដូចមុន* ត្រង់កថាខណ្ឌទី ៣១ ។

៩. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចជាឯកច្ឆន្ទថា ផលវិបាកចាំបាច់នៃការផ្អាកកិច្ចដំណើរការនីតិវិធី គឺថា "ពុំមានមូលដ្ឋានណាមួយ ដើម្បីបន្តឃុំខ្លួនជនជាប់ចោទតទៅទៀតបានទេ"[13]។ នៅក្នុងការធ្វើសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការពិចារណាទូទៅ និងមានកម្រិត តែទៅលើវិធាននីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិប៉ុណ្ណោះ។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងបានបង្វែរទាំងស្រុងឱ្យឃ្លាតចេញពីយុត្តិសាស្ត្រ និងការអនុវត្តរបស់តុលាការអន្តរជាតិ និងតុលាការនានាដែលត្រូវបានធ្វើឱ្យទៅជាអន្តរជាតិផ្សេងៗទៀត ខណៈដែលការមិនមានសម្បទាក្នុងការចូលរួមសវនាការ *ជាទូទៅ មិន*បណ្តាលឱ្យមានការបញ្ចប់មួយដ៏មានប្រសិទ្ធភាពទៅលើកិច្ចដំណើរការនីតិវិធី តាមរយៈការដោះលែងដោយគ្មានលក្ខខណ្ឌនោះឡើយ។ ក៏ប៉ុន្តែផ្ទុយទៅវិញ បានបណ្តាលឱ្យមានការផ្អាកកិច្ចដំណើរការនីតិវិធីមួយជាបណ្តោះអាសន្ន ដោយស្ថិតនៅក្រោមការដាក់វិធានការត្រួតពិនិត្យដ៏ម៉ឺងម៉ាត់ តាមផ្លូវតុលាការ។ វិធានការបែបនេះធ្លាប់ត្រូវបានអនុវត្តរួចមកហើយ សូម្បីតែនៅក្នុងករណីមានជម្ងឺដំណាក់កាល *ចុងក្រោយ* ក៏ដោយ គឺមិនមែនគ្រាន់តែមានជម្ងឺដែលមាន"លក្ខណៈដែលចេះតែវិវឌ្ឍ និងចុះដុនដាបជាលំដាប់"[14] ដូចជាជម្ងឺដែលជនជាប់ចោទកំពុងតែប្រឈមមុខ។

១០. តាមវិធីពន្យល់ដោយមានឧទាហរណ៍បញ្ជាក់ នៅក្នុងករណីរឿងក្តីរបស់ *Đukić,* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានថ្លែងថា៖

> *ទោះបីជាហេតុផលបញ្ជាក់របស់ផ្នែកពេទ្យដែលបានលើកយកមកសំអាងអាចនឹងសភាពធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏មិនមានអ្វីនៅក្នុងលក្ខន្តិកៈ ឬនៅក្នុងវិធានផ្ទៃក្នុងដែលអនុញ្ញាតឱ្យដកមូលហេតុទាំងនោះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបានចោទប្រកាន់ពីបទឧក្រិដ្ឋធំៗ ដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិត្រូវតែវិនិច្ឆ័យនោះឡើយ ហេតុដូចនេះ គឺគ្មានហេតុផលណាដែលត្រូវផ្តល់ការអនុញ្ញាតឱ្យរដ្ឋអាជ្ញាដកការចោទប្រកាន់ឡើយ*[15]។

---

[13] **E138** សេចក្តីសម្រេចដែលរងការជំទាស់, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌទី ៦១ ។

[14] **E138** សេចក្តីសម្រេចដែលរងការជំទាស់, *ដដែលដូចមុន* ។

[15] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Đorđe Đukić*, សំណុំរឿងលេខ IT-96-20-T, សេចក្តីសម្រេចស្តីពីការបដិសេធលើពាក្យសុំដកទៅវិញនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះនិងដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី២៤ មេសា ១៩៩៦ ត្រង់ចំណុចលេខ៣។

១១. ស្រដៀងគ្នានេះ នៅក្នុងករណីរឿងក្ដីរបស់ *Talić* ទោះបីជាជនជាប់ចោទត្រូវបានអនុញ្ញាតឱ្យដោះលែងជាបណ្ដោះអាសន្ន ដោយសារលទ្ធផលនៃជម្ងឺស្ថិតនៅក្នុងដំណាក់កាលចុងក្រោយនោះក្ដី ក៏ដំណើរការនីតិវិធីមិនទាន់បញ្ចប់ដែរ រហូតទាល់តែក្រោយពេលគាត់ស្លាប់ទើបបានបញ្ចប់[16]។ នៅក្នុងករណីរឿងក្ដីរបស់ *Kovačević* ចុងចោទត្រូវបានគេរកឃើញថា មិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមនៅក្នុងសវនាការបានទេ ដោយសារមូលហេតុខាងរោគចិត្តវិកលវិទ្យា ប៉ុន្តែមានញត្តិរបស់មេធាវីការពារក្ដីមួយដែលស្នើសុំឱ្យបដិសេធការចោទប្រកាន់ ត្រូវបានច្រានចោល[17]។

១២. គោលការណ៍ដដែលនេះក៏ត្រូវបានយកមកអនុវត្តផងដែរដោយគណៈវិនិច្ឆ័យពិសេសសម្រាប់ឧក្រិដ្ឋកម្មពិសេសនានា នៅទីម័រខាងកើត។ នៅក្នុងករណីរឿងក្ដីរបស់ *Nahak* គណៈវិនិច្ឆ័យពិសេសបានសម្រេចថា៖

> *ការកំណត់ថា ចុងចោទមិនមានសមត្ថភាពដើម្បីចូលរួមនៅក្នុងសវនាការបាននោះ មិនមែនជាការការពារចំពោះការចោទប្រកាន់ផ្សេងៗប្រឆាំងនឹងគាត់នោះទេ។ តែផ្ទុយទៅវិញ គឺវាដំណើរការក្នុងនាមជារបាំងរារាំង ចំពោះការចាប់ផ្ដើម ឬការបន្តការជំនុំជម្រះក្ដីលើរូបគាត់ ... ការជំនុំជម្រះក្ដីរបស់ចុងចោទអាចចាប់ផ្ដើមបាន សូម្បីតែនៅក្រោយពីរយៈពេលនៃការព្យួរក៏ដោយ បើសិនជាការមិនមានសម្បទាគ្រប់គ្រាន់របស់ចុងចោទបង្ហាញសុក្ខីកម្មថា មានលក្ខណៈជាបណ្ដោះអាសន្ននោះ[18]។*

១៣. បន្ទាប់ពីការរកឃើញថាគ្មានសម្បទា មានករណីភាគច្រើនបានគាំទ្រចំពោះការបង្គាប់ឱ្យព្យាបាលជម្ងឺដោយវេជ្ជសាស្ត្រ ដើម្បីឱ្យជនជាប់ចោទមានកាយសម្បទាគ្រប់គ្រាន់ឡើងវិញ ដើម្បីអាចចូលរួមនៅក្នុងសវនាការសារជាថ្មីម្ដងទៀត។ *នៅក្នុងករណីរឿងក្ដីរបស់* Stanišić សវនាការត្រូវបាន

---

[16] *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង Radolav Brđanin និង Momir Talić*, សំណុំរឿងលេខ IT-99-36-T, ដីកាសម្រេចបញ្ឈប់ដំណើរការនីតិវិធីប្រឆាំងនឹងឈ្មោះ Momir Talić (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី១២ មិថុនា ២០០៣។

[17] *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង Vladimir Kovačević*, សំណុំរឿងលេខ IT-01-42/2-I, សេចក្ដីសម្រេចលើ "សំណើសុំការចុះហត្ថលេខាបញ្ជាក់របស់មេធាវីការដើម្បីឱ្យប្ដឹងសាទុក្ខលើបញ្ហាបន្ទាន់បង្ខំប្រឆាំងនឹង 'សេចក្ដីសម្រេចលើញត្តិរបស់មេធាវីការពារក្ដីដែលស្នើសុំឱ្យបដិសេធនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ' ចាប់តាំងពីថ្ងៃទី១កញ្ញា ២០០៦ តទៅ" (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY) ចុះថ្ងៃទី២៧ កញ្ញា ២០០៦។

[18] *អគ្គរដ្ឋអាជ្ញារងទទួលបន្ទុកបទល្មើសធ្ងន់ធ្ងរ ទល់នឹង Josep Nahak*, សំណុំរឿងលេខ 01A/2004, ការរកឃើញនានា និងដីកាសម្រេចស្ដីពីសមត្ថភាពសម្បទារបស់របស់ចុងចោទឈ្មោះ Nahak ដើម្បីចូលរួមនៅក្នុងសវនាការ ( គណៈកម្មការវិនិច្ឆ័យពិសេសសម្រាប់បទល្មើសធ្ងន់ធ្ងរនានា (ទីម័រខាងកើត) ចុះថ្ងៃទី១ មីនា ២០០៥ ត្រង់កថាខណ្ឌទី១៥៥-១៥៧។

លើកពេល ដោយសារតែសម្បទាខាងផ្លូវកាយ និងផ្លូវស្មារតីរបស់ជនជាប់ចោទ ដែលអង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់ថា "ឈឺធ្ងន់"[19]។ ថ្វីបើការកំណត់របស់ខ្លួនថា "រយៈពេល មុន...ការចាប់ផ្តើម[នៃដំណើរការសវនាការ]មានភាពមិនប្រាកដប្រជា និងមិនមានការកំណត់កាលបរិច្ឆេទ"[20] អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបង្គាប់ឲ្យយកជនជាប់ចោទទៅសំរាកព្យាបាលនៅក្នុងមន្ទីរពេទ្យ និងឲ្យវេជ្ជបណ្ឌិតទាំងឡាយដែលព្យាបាលជម្ងឺគាត់ ធ្វើបច្ចុប្បន្នភាពជូនអង្គជំនុំជម្រះជាទៀងទាត់[21]។

១៤. *នៅក្នុងករណីរឿងក្តីរបស់* Kovačević ជនជាប់ចោទបានទទួលរងការឈឺចាប់ដោយសារជម្ងឺវិបល្លាសស្មារតីដែលគ្មានកំណត់សក្តានុពលច្បាស់លាស់។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា "ការព្យាបាលជម្ងឺ-ក្រៅពីការផ្តល់ថ្នាំធ្វើឲ្យធូរស្រាលដល់អ្នកណាម្នាក់ដែលមានសេចក្តីត្រូវការចាំបាច់ និងអ្នកដែលមានសិទ្ធិត្រូវទទួលការព្យបាលនេះ-ក៏វាជាការចាំបាច់ដែរ... ដើម្បីធ្វើឲ្យប្រាកដថាតើជនជាប់ចោទក្រោយពីបានទទួលនូវការព្យាបាលជម្ងឺគ្រប់គ្រាន់ហើយនោះ អាចនឹងមានសមត្ថភាពចូលរួមនៅក្នុងសវនាការនាពេលអនាគតបានដែរ ឬទេ?"[22]។

១៥. យុត្តិសាស្ត្ររបស់តុលាការ ICTY បានបង្ហាញឲ្យឃើញថា ក្នុងការអនុញ្ញាតឲ្យផ្អាកជាបណ្តោះអាសន្ននូវដំណើរការនីតិវិធី ដោយសារហេតុផលមានជម្ងឺ ដែលត្រូវបានព្យាបាលដោយ វេជ្ជសាស្ត្រនោះ អង្គជំនុំជម្រះសាលាដំបូងមិនគួរផ្តោតទាំងស្រុងទៅលើតែផលប្រយោជន៍ខាងសេរីភាពរបស់ជនជាប់ចោទតែមួយមុខប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវធានាដើម្បីឲ្យជនជាប់ចោទទទួលបាននូវការព្យាបាលជម្ងឺដោយផ្នែកពេទ្យឲ្យបានត្រឹមត្រូវ នៅក្នុងបរិយាកាសប្រសើរជាងគេបំផុតដែលនាំទៅរកការជាសះស្បើយឡើងវិញ។ ដូចដែលបានធ្វើការកត់សំគាល់ខាងលើស្រាប់ នេះគឺជាវិធីសាស្ត្រដែលគេបានប្រកាន់យក សូម្បីតែនៅក្នុងពេលដែលជនជាប់ចោទ *មិនទំនងជានឹង*ជាសះស្បើយឡើងវិញក៏ដោយ។

---

[19] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Jovica Stanišić*, សំណុំរឿងលេខ IT-03-69-T, សេចក្តីសម្រេចស្តីពីការដោះលែងឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី២៦ ឧសភា ២០០៨ ត្រង់កថាខណ្ឌទី៦០។

[20] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៦២។

[21] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៦៨(១)(ឃ)(viii) និង៦៨(២)។

[22] *ដូចគ្នានឹងខាងលើ* ត្រង់ទំព័រ១។

១៦. *នៅក្នុងករណីរឿងក្តីរបស់ Stanišić* ទោះបីជាជនជាប់ចោទត្រូវបានតុលាការសម្រេចថាមិនមានសម្បទាក៏ដោយ ក៏អង្គជំនុំជម្រះបានចេញដីកាបង្គាប់មួយទៅឱ្យអ្នកជំនាញខាងចិត្តសាស្ត្រដែលតុលាការបានតែងតាំង ឱ្យពិនិត្យមើលជនជាប់ចោទនៅឯ UNDU នៅក្នុងទីក្រុងឡាអេ ហើយឱ្យរាយការណ៍ជូនអង្គជំនុំជម្រះនៅរៀងរាល់បីសប្តាហ៍ម្តង[23]។ ករណីនេះលុះត្រាតែនៅពេលក្រោយពីមានពាក្យសុំដោះលែងជាបណ្តោះអាសន្នមួយបន្ទាប់មកទៀត ទើបអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យមានការដោះលែង ហើយបញ្ជូនទៅឱ្យទីក្រុងបែលហ្ក្រាដ ជាបឋមគឺចង់ឱ្យទៅពេទ្យព្យាបាលជម្ងឺ។ ស្រដៀងគ្នានេះ *នៅក្នុងករណីរឿក្តីរបស់ Strugar* ដែលទោះបីជាមានការរកឃើញមួយដែលមិនអាចប្រកែកបានក៏ដោយ ជនជាប់ចោទចាំបាច់ត្រូវការឱ្យពេទ្យព្យាបាលជម្ងឺក្តី[24] អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបដិសេធពាក្យសុំ ដើម្បីឱ្យពេទ្យព្យាបាលជម្ងឺ ដែលបានធ្វើឡើងនៅក្រៅពីរបបនៃការដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នរបស់តុលាការដែរ។ គ្មានករណីណាមួយក្នុងចំណោមករណីទាំងនេះ ដែលចុងចោទត្រូវបានដោះលែងជាបណ្តោះអាសន្ននោះឡើយ រហូតទាល់តែពួកគេបង្ហាញអាចភ័ស្តុតាងថា ពួកគេបានបំពេញតាមលក្ខខណ្ឌតម្រូវនានាអនុលោមតាមវិធានផ្ទៃក្នុងសិន ហើយថាការដោះលែងរបៀបនេះគឺត្រូវតែបានធ្វើយុត្តិកម្មដោយមានការបញ្ជាក់ពីផ្នែកពេទ្យ។

១៧. *នៅក្នុងករណីរឿក្តីរបស់ Mrđa* អង្គជំនុំជម្រះសាលាដំបូង បានកត់សំគាល់ថា ច្បាប់សិទ្ធិមនុស្សអន្តរជាតិចែងថាការឃុំខ្លួនតាមនីតិន័យនៅមុនពេលសវនាការ គួរតែជាករណីលើកលែង ហើយមិនមែនជាវិធាននោះទេ។ ប៉ុន្តែអង្គជំនុំជម្រះបានថ្លែងទាក់ទងនឹងវិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY ថា៖

> *មិនដូចតុលាការជាតិនានាទេ តុលាការអន្តរជាតិមិនមានអំណាច ដើម្បីបង្ខិតបង្ខំឱ្យអនុវត្តសេចក្តីសម្រេចឡើយ ហើយដោយសារមូលហេតុនេះ ការឃុំខ្លួនជាបណ្តោះអាសន្នហាក់*

---

[23] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Jovica Stanišić*, សំណុំរឿងលេខ IT-03-69-T, សេចក្តីសម្រេចស្តីពីការដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ( អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY) ចុះថ្ងៃទី២៦ ឧសភា២០០៨ ត្រង់កថាខណ្ឌទី៨, ដែលដកស្រង់ពីសវនាការកាលពីថ្ងៃទី២០ ឧសភា២០០៨។

[24] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Pavle Strugar*, សំណុំរឿងលេខIT-01-42-A, សេចក្តីសម្រេចលើ "ញត្តិរបស់មេធាវីការពារក្តី: សំណើសុំផ្តល់នូវជំនួយផ្នែកវេជ្ជសាស្ត្រនៅក្នុងសាធារណរដ្ឋ Montenegro នៅក្នុងស្ថានភាពកំពុងជាប់ឃុំ", (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី៨ ធ្នូ ២០០៥។

*ដូចជា តាមការជាក់ស្តែងជាវិធាននៅក្នុងតុលាការទៅវិញ ទើបវាប្រសើរជាង។ លើសពីនេះ គេត្រូវតែយកចិត្តទុកដាក់ចំពោះប្រការដែលថា ឈ្មោះពេញរបស់តុលាការបានបញ្ជាក់តែអំពីឧក្រិដ្ឋកម្ម "ធ្ងន់ធ្ងរ"តែប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ ការទុកឱ្យសិទ្ធិមនុស្សដែលបានលើកបញ្ជាក់ពីខាងដើម នៅដដែលដោយគ្មានការផ្លាស់ប្តូរ ប៉ុន្តែយកមកប្រើដោយជាក់លាក់ ដើម្បីគោលបំណងផ្សេងៗរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិទៅវិធាន៦៥ នៃវិធានផ្ទៃក្នុង បានអនុញ្ញាតឱ្យដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន។ ប្រព័ន្ធណាមួយនៃការឃុំខ្លួនជាចាំបាច់ដោយខានមិនបាន ដោយការបញ្ជូនត្រឡប់ឱ្យទៅកាន់កន្លែង គឺឃុំឃាំងវិញ គឺមានវិសមិតភាពដោយខ្លួនឯងផ្ទាល់ជាមួយនឹងមាត្រា៥(៣)នៃអនុសញ្ញា[ទ្វីបអឺរ៉ុប]។ ដោយយល់ឃើញអំពីរឿងនេះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែបកស្រាយវិធាន៦៥ នៃវិធានផ្ទៃក្នុង ថាមិនមែនជាអរូបីយនោះឡើយ តែវាទាក់ទងទៅនឹងមូលដ្ឋានខាងអង្គហេតុនៃករណីតែមួយគត់ និងពាក់ព័ន្ធនឹងស្ថានភាពជាក់ស្តែងរបស់បុគ្គលអ្នកដាក់ពាក្យសុំទៀតផង[25] ។*

១៨. វិធីសាស្ត្រនេះក៏ស្របគ្នាផងដែរជាមួយនឹងព្រំដែនកំណត់នៃការវាយតម្លៃ ដែលបានផ្តល់ទៅឱ្យរដ្ឋនានាដែលស្ថិតនៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលទូទៅជាងនេះ នៅពេលវាយតម្លៃអំពីនីត្យានុកូលភាពនៃការបង្ខាំង និងការព្យាបាលជម្ងឺរបស់ជនទាំងឡាយដែលមានជម្ងឺខាងស្មារតីដែលជាការចាំបាច់ខានមិនបាន។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានទទួលស្គាល់ថា ការបង្ខាំងជនណាម្នាក់នៅកន្លែងណាមួយរបស់ពេទ្យដើម្បីព្យាបាលជម្ងឺ គឺមិនចាំបាច់ធ្វើយុត្តិកម្មតាមវិធីសាស្ត្រនៃការព្យាបាលជម្ងឺដែលជននោះត្រូវការតែមួយប៉ុណ្ណោះនោះទេ។ ការបង្ខាំងដែលចាំបាច់ខានមិនបានដែលកំណត់ដោយច្បាប់ក្នុងស្រុក គឺមិនមែនជាការឃុំខ្លួនតាមទំនើងចិត្តឡើយ បើសិនជននោះត្រូវការឱ្យមាន "ការត្រួតមើលពីលើ និងការត្រួតពិនិត្យ"ដើម្បីមូលហេតុផ្សេងៗទៀតដូចជាការទប់ស្កាត់កុំឱ្យមានការខូចខាតដល់អ្នកដទៃ[26]។ កត្តាបែបនេះក្នុងចំណោមកត្តាដទៃៗទៀតជាច្រើន ដែលត្រូវបានតម្កល់ទុកនៅក្នុងបទបញ្ញត្តិដែលទាក់ទងនឹងការដោះលែងជាបណ្តោះ

[25] *ដូចគ្នានឹងខាងលើ។*

[26] *ករណីរឿងក្តីរបស់ Witold Litwa ទល់នឹង ប្រទេសប៉ូឡូញ* , សំណុំរឿងលេខ 26629/95 (ផ្នែកទី២), តុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុប ឆ្នាំ ២000-III ត្រង់កថាខណ្ឌទី៦០។ *ករណីរឿងក្តីរបស់ Hutchinson Reid ទល់នឹង ប្រទេសអង់គ្លេស,* សំណុំរឿងលេខ 50272/99, [ឆ្នាំ ២០០៣] តុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុប ៩៤ (ចុះថ្ងៃទី២០ កុម្ភៈ ២០០៣) ត្រង់កថាខណ្ឌទី៥១។

អាសន្ន នៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិនិត្យពិចារណាដោយត្រឹមត្រូវ[27]។

### *(ii) ជាកំហុសខាងអង្គហេតុដែលបើកឱកាសឲ្យមានការប្រព្រឹត្តខុសនឹងយុត្តិធម៌ និងកំហុសដែលអាចឲ្យយល់ដឹងបាននៅក្នុងការអនុវត្តឆន្ទានុសិទ្ធិ*

១៩. ដោយយោងទៅលើកថាខណ្ឌទី១៥ និង១៦នៃបណ្តឹងសាទុក្ខដែលក្នុងនោះភ័ស្តុតាងត្រូវបានបង្កើតសូម្បីតែលទ្ធភាពក្នុងការធ្វើឲ្យកាន់តែប្រសើរឡើងក្នុងស្ថានភាពនៃការព្យាបាលផ្នែកពេទ្យរបស់ជនជាប់ចោទតាមរយៈការជួយជំរុញខាងផ្លូវចិត្តជាបន្ថែម វិធីព្យាបាលដោយមិនប្រើថ្នាំតាមបែបអាជីពឬដំណើរការក្នុងការប្រើថ្នាំ ដូចជានៅក្នុងករណីនេះ ឆន្ទានុសិទ្ធិមួយរបស់អង្គជំនុំជម្រះសម្រាប់ធ្វើការវាយតម្លៃទៅលើតម្លៃភ័ស្តុតាងនៃសក្ខីកម្មរបស់អ្នកជំនាញ[28] មិនអាចលាតសន្ធឹងដោយត្រឹមត្រូវរហូតទៅដល់ការមិនយកចិត្តទុកដាក់ចំពោះសក្ខីកម្មដែលអាចឲ្យជឿទុកចិត្តបាននៃសាក្សីជំនាញនានារបស់ខ្លួនផ្ទាល់ទៅលើការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ ដែលជាស្នូលរបស់សមត្ថភាពខាងវិជ្ជាជីវៈរបស់អ្នកជំនាញរូបនោះបានទេ។

២០. ក្នុងករណីនេះ មានអ្នកជំនាញមួយរូបបានលើកឡើងនូវអនុសាសន៍ ដោយមានការមិនយល់ព្រមពីអ្នកជំនាញដទៃទៀតថា ការជំនុំជម្រះក្តីរយៈពេលបីខែលើករណីរបស់ *donepezil* គួរតែត្រូវបានព្យាយាមដើម្បីកំណត់ បើសិនជាការណ៍នេះនឹងធ្វើឲ្យស្ថានភាពរបស់ជនជាប់ចោទមានភាពកាន់តែល្អប្រសើរថែមទៀត និងថាភាពកាន់តែល្អប្រសើរណាមួយអាចនឹងសម្រេចបាន នៅក្នុងពេលអនាគត ពីរ ឬច្រើនឆ្នាំទៅមុខទៀត[29]។ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសទាំងខាងអង្គហេតុផង និងទាំងនៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនផង ដោយមិនបានពិចារណារបាយការណ៍វាយតម្លៃរបស់អ្នកជំនាញ។

---

[27] ឯកសារលេខ **E138/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់លេខ ២ *ខាងដើម* ត្រង់កថាខណ្ឌពីទី៩-១១ ។

[28] សូមអាន *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Pavle Strugar*, សំណុំរឿងលេខ IT -99-36-T, សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាដាក់នូវចម្លើយរបស់សាក្សីអ្នកជំនាញឈ្មោះ Ewan Brown (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី៣ មិថុនា ២០០៣ ត្រង់ទំព័រទី៤។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Casimir Bizimungu* និងគូរកន, សំណុំរឿងលេខ ICTR-99-50-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីដែលស្នើសុំឲ្យដកចេញនូវចំណែកមួយចំនួននៃសក្ខីកម្មរស់សាក្សីជំនាញលោកបណ្ឌិត Alison des Forges (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR), ចុះថ្ងៃទី២ កញ្ញា ២០០៥ ត្រង់កថាខណ្ឌទី១៩។

[29] ឯកសារលេខ **E1/9.1** ប្រតិចារឹក, ចុះថ្ងៃទី៣០ សីហា ២០១១ ត្រង់ទំព័រ៦៧។

២១. អង្គជំនុំជម្រះហាក់ដូចជាបានសន្និដ្ឋានថា ការសាកល្បងប្រើថ្នាំ *Donepezil* មិនអាចធ្វើទៅបាន ដោយផ្អែកលើមូលដ្ឋានថា ថ្នាំពេទ្យប្រភេទនេះមិនអាចរកបាននៅប្រទេសកម្ពុជា។ ការរកឃើញដូច្នេះ គ្រាន់តែជាការមិនយកតាមភស្តុតាងរបស់សាស្ត្រាចារ្យ Campbell ។ សាស្ត្រាចារ្យបានផ្តល់អនុសាសន៍ឱ្យសាកល្បងប្រើថ្នាំនេះ ដោយហេតុថា គាត់មកប្រទេសខ្មែរពីរដង និងធ្លាប់បានពិភាក្សាយ៉ាងទូលំទូលាយជាមួយក្រុមគ្រូពេទ្យ ដែលបានព្យាបាលជនជាប់ចោទតាំងពីឆ្នាំ២០០៧មក។ នៅក្នុងការផ្តល់អនុសាសន៍ឱ្យសាកល្បងប្រើថ្នាំ *Donepezil* សាស្ត្រាចារ្យ Campbell បានដឹងអំពីប្រភេទសេវាកម្មវេជ្ជសាស្ត្រដែលមាននៅកម្ពុជា ជាពិសេសនៅ អ.វ.ត.ក។ ត្រឹមកម្រិតនេះ វេជ្ជបណ្ឌិត Fazel និង វេជ្ជបណ្ឌិត Lina បានប្រុងទុកចំពោះការប្រើថ្នាំ *Donepezil* ការបម្រុងទុកនេះត្រូវតែវាយតម្លៃធៀបនឹងការពិតដែលថា ពួកគាត់បានទទួលស្គាល់នៅក្នុងរបាយការណ៍របស់ខ្លួនថា ពួកគាត់មានបទពិសោធន៍នៅមានកម្រិតអំពីការប្រើថ្នាំប្រភេទនេះ និងសក្ខីកម្មដែលពួកគាត់បានផ្តល់ផ្ទាល់មាត់ថា ពួកគាត់មិនមែនមិនយល់ស្របតាមវេជ្ជបណ្ឌិត Campbell នៅលើបញ្ហានេះទេ[30]។ ជាងនេះ គេមិនច្បាស់ថា ទោះបីជាថ្នាំ *Donepezil* មិនអាចរកបាននៅកម្ពុជាក៏ដោយ និង/ឬ បើសិនជាបទពិសោធន៍ក្នុងការប្រើឱសថប្រភេទនេះនៅមានកម្រិតក៏ដោយ នេះមិនអាចជំនះបញ្ហានេះបានតាមរយៈការស្វែងរកពីបរទេស និងធ្វើកិច្ចសន្យាជាមួយអ្នកជំនាញណាម្នាក់ ដូចសាស្ត្រាចារ្យ Campbell ជាដើម ដើម្បីឱ្យតាមដានលើការគ្រប់គ្រងរដ្ឋបាលរបស់វា។ ទោះក្នុងករណីណាក៏ដោយ នៅក្នុងកាលៈទេសៈដែលគ្មានឧបសគ្គណាមួយជាក់ស្តែងដែលលើកឡើងដោយអ្នកជំនាញណាម្នាក់ អំពីការអនុវត្តសាកល្បងក្នុងការប្រើថ្នាំប្រភេទនេះនៅក្នុងកាលៈទេសៈបច្ចុប្បន្ន និងបើសិនជាគ្មានការព្យាយាមគ្រប់គ្រងរដ្ឋបាលលើការព្យាបាលដូច្នេះ គេគ្មានហេតុផលណាសម្រាប់អង្គជំនុំជម្រះសន្និដ្ឋានជាចុងក្រោយថា មធ្យោបាយដូច្នេះមិនអាចរកបាននោះទេ។

២២. អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំបន្ថែមទៀត តាមរយៈការខកខានមិនបានគិតគូរពីភាពប្រសើរឡើងនៃមុខងារចងចាំរបស់ជនជាប់ចោទ ដែលទំនងជានឹងកើតចេញពីភាពធូរស្រាលពីបុព្វហេតុដែលអាចមាន ឬកត្តាស្ថានទម្ងន់ផ្សេងៗទៀត។ ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះបង្ហាញឱ្យឃើញថា លក្ខខណ្ឌឃុំឃាំង*បច្ចុប្បន្ន* របស់ជនជាប់ចោទ ផ្តល់ឱ្យមានរំញោចខាងបញ្ញា

[30] **E1/12.1** ប្រតិចារឹកសវនាការ, ២០ តុលា ២០១១, ត្រង់ទំព័រទី៥៤ ។

ស្មារតីនៅមានកម្រិត[31] ហើយវេជ្ជបណ្ឌិត Fazel បានផ្តល់សក្ខីកម្មថា "ការជំរុញនៃការចងចាំគឺជាផ្នែកមួយដ៏សំខាន់នៃការព្យាយាមដែលយ៉ាងហោចណាស់ ក៏អាចបន្ថយអាត្រានៃការចុះខ្សោយខាងការចងចាំ"[32]។ ច្បាស់ណាស់ថា ការប្រើកម្មវិធី និងការធ្វើសម្បទាឡើងវិញ ដែលបានរៀបចំឡើងដោយប្រុងប្រយ័ត្ន គឺជាវិធានការមួយដ៏សមស្របដែលគួរតែព្យាយាម រួមជាមួយនឹងការសាកល្បងប្រើថ្នាំ *Donepezil* ពីព្រោះថា ទាំងពីររបៀបនេះអាចផ្តល់លទ្ធភាពឲ្យជនជាប់ចោទ អាចចូលរួមបាននៅក្នុងកិច្ចដំណើរការនីតិវិធី និងដោយសារផលប្រយោជន៍ផ្ទាល់របស់គាត់។ ចៅក្រមកម្ពុជានៃអង្គជំនុំជម្រះសាលាដំបូងមានការរកឃើញជាឯកច្ឆន្ទថា ការព្យាបាលដោយមិនប្រើថ្នាំតាមបែប Therapy ដែលការពិត ការព្យាបាលរបៀបនេះ ជាទម្លាប់នៃការអនុវត្តជាអាជីពនៅកម្ពុជា ផ្ទុយនឹងអ្វីដែលបាននិយាយក្នុងរបាយការណ៍របស់វេជ្ជបណ្ឌិត Fazel និងវេជ្ជបណ្ឌិត Lina[33] និងការរកឃើញរបស់ចៅក្រមអន្តរជាតិ[34]។

២៣. អង្គជំនុំជម្រះក៏ខកខានផងដែរ ក្នុងការផ្តល់ទម្ងន់ឲ្យបានគ្រប់គ្រាន់អំពីកត្តាខាងក្រោមនេះ នៅក្នុងការវាយតម្លៃអំពីអង្គហេតុរបស់ខ្លួនចំពោះលទ្ធភាពនៃការជាសះស្បើយឡើវិញរបស់ជនជាប់ចោទ៖

(ក) ការពិតដែលថា លទ្ធភាពនៃការប្រព្រឹត្តិរបស់ជនជាប់ចោទអាចនឹងប្រសើរឡើងវិញ តាមរយៈការប្រើប្រាស់ឯកសារ និងជំនួយផ្សេងៗ[35]ដើម្បីឲ្យការចងចាំរបស់គាត់ស្រស់ស្រាយ និងតាមរយៈការធ្វើលំហាត់សមផ្សេងៗ (ភ័ស្តុតាងបញ្ជាក់ច្បាស់ថា លទ្ធភាពប្រព្រឹត្តិរបស់ជនជាប់ចោទកាន់តែប្រសើរឡើង នៅពេលមានការពិនិត្យសាចុះសាឡើង)[36]។

(ខ) ការពិតដែលថាជនជាប់ចោទអាចរក្សាបាននូវលទ្ធភាពក្នុងការប្រាស្រ័យទាក់ទង យល់អំពីព័ត៌មានផ្សេងៗដែលបានបញ្ជូនមកគាត់ និងបញ្ចេញឲ្យឃើញច្បាស់អំពីខ្លួនរបស់គាត់តាម

[31] **E1/12.1** ប្រតិចារឹកសវនាការ, ២០ តុលា ២០១១, ត្រង់ទំព័រទី៥២-៥៣ ។

[32] *ដដែលដូចខាលើ*, ត្រង់ទំព័រទី៥៣ ។

[33] **E138** សេចក្តីសម្រេចដែលកំពុងរងការជំទាស់នេះ, កំណត់សម្គាល់*ខាងដើម* លេខ ១ ត្រង់កថាខ័ណ្ឌទី៦៥ ។

[34] **E138** សេចក្តីសម្រេចដែលកំពុងរងការជំទាស់នេះ, *ដដែលដូចខាងលើ,* ត្រង់កថាខ័ណ្ឌទី៧២ ។

[35] *ដដែលដូចខាងលើ,* ត្រង់ទំព័រទី៤៦ ។

[36] *ដដែលដូចខាងលើ,* ត្រង់ទំព័រទី៤២-៤៤ ។

វយៈការផ្តល់ចម្លើយផ្សេងៗបានសមស្រប រួមទាំងនៅក្នុងភាសាអង់គ្លេស និងបារាំង[37] និង

(គ) ការពិតដែលថា ជនជាប់ចោទនៅអាចរក្សាបាននូវលទ្ធភាពក្នុងការពិភាក្សាពីបញ្ហាផ្សេងៗ ដែលគាត់បានអានពីសារព័ត៌មានផ្សេងៗ និងយល់អំពីសារៈសំខាន់របស់វា[38]។

## *(iii) ដោយហេតុថា ការភាន់ច្រឡំដែលគេអាចមើលឃើញតាមរយៈការប្រើឆន្ទានុសិទ្ធិ បណ្តាលឲ្យមានការជំទាស់*

២៤. តាមការយោងទៅនឹងកថាខណ្ឌទី១៧ និង១៨ នៃបណ្តឹងសាទុក្ខ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការដាក់លក្ខខណ្ឌដ៏តឹងរ៉ឹងទៅលើជនជាប់ចោទ ដែលកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជននេះត្រូវបានផ្អាក ជាការបន្ថែមលើសេចក្តីពិចារណាដែលមានចែងក្នុងវិធាន២១(២) ត្រូវតែឲ្យមានតុល្យភាពទៅនឹងសិទ្ធិក្នុងការទទួលបានសេរីភាព; ផលប្រយោជន៍ផ្លូវច្បាប់ និងសុវត្ថិភាពរបស់ជនរងគ្រោះ សាក្សី និងសហគមន៍[39] និងភារកិច្ចរបស់រដ្ឋ និងផលប្រយោជន៍ផ្លូវច្បាប់របស់សហគមន៍អន្តរជាតិ នៅក្នុងការចោទជនទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មអន្តរជាតិដ៏សំខាន់នានា[40]។

២៥. ជាពិសេស ការខកខានក្នុងការស្វែងរកលទ្ធភាពផ្សេងៗឲ្យអស់លទ្ធភាព ទោះជាពីចម្ងាយ ដើម្បីធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌរបស់ជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់ទម្ងន់ឲ្យបានគ្រប់គ្រាន់ចំពោះសិទ្ធិជំទាស់ និងផលប្រយោជន៍ខាងផ្លូវច្បាប់ដែលទទួលរងផលប៉ះពាល់។ គោលការណ៍ជាមូលដ្ឋាននៃច្បាប់ទម្លាប់អន្តរជាតិ តំណាងឲ្យភាពចាំបាច់ក្នុងការស្វែងរកឲ្យអស់លទ្ធភាពនូវជម្រើសផ្សេងៗតាមលទ្ធភាពដែលអាចធ្វើទៅបាន ដោយមានការថ្លឹងថ្លែងអំពីសិទ្ធិរបស់ជនជាប់ចោទជាមួយនឹង "សិទ្ធិមិនអាចកាត់ផ្តាច់បាន ដើម្បីបានដឹងអំពីការពិតនៃព្រឹត្តិការណ៍ដែលបានកើត

[37] *ដដែលដូចខាងលើ,* ត្រង់ទំព័រទី៤៦-៤៨ ។

[38] *ដដែលដូចខាងលើ,* ត្រង់ទំព័រទី៤៨-៤៩ ។

[39] **C11/53** សាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, ២០ មីនា ២០០៨ ត្រង់កថាខណ្ឌទី៣១ ។ សូមអានផងដែរ មាត្រា៣៣ថ្មី នៃច្បាប់ អ.វ.ត.ក; វិធាន២១(១)(គ); វិធាន២៩ នៃវិធានផ្ទៃក្នុង ។

[40] **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ១១ មេសា ២០១១ ត្រង់កថាខណ្ឌទី១៤៣ ។

ឡើងពីអតីតកាលរបស់ប្រជាជនកម្ពុជា ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋដ៏សាហាវយង់ឃ្នង និង អំពីកាលៈទេសៈ និងមូលហេតុផ្សេងៗដែលនាំឲ្យមាន... ការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ"[41]។ អង្គជំនុំជម្រះសាលាដំបូងមានភារកិច្ចជាមូលដ្ឋាន ដើម្បីចាត់ការរកយុត្តិធម៌ ក្នុងករណីមានអំពើឃោរឃៅយង់ឃ្នងកើតឡើង ដូចទំហំអំពើឃោរឃៅដែលមានចែងក្នុងដីកាដំណោះស្រាយ[42]។

២៦. ដោយមានការគិតគូរអំពីសិទ្ធិ និងផលប្រយោជន៍ផ្លូវច្បាប់ដែលពាក់ព័ន្ធ បន្ថែមលើការធ្វើសវនាការជាមួយភាគីនានា នៅពេលណាក៏ដោយដែលមានភាពមិនប្រាកដប្រជាខាងផ្លូវច្បាប់ ចំពោះជនជាប់ចោទដែលកើតចេញពីការផ្អាកដំណើរការនីតិវិធី ក៏អាចនឹងកាត់បន្ថយជាអប្បបរមា តាមរយៈការទទួលយកការវាយតម្លៃវេជ្ជសាស្ត្រ ដោយផ្អែកតាមការកំណត់ពេលវេលាជាក់លាក់ ការអនុញ្ញាតឲ្យមានសំណើពិនិត្យឡើងវិញពីលក្ខខណ្ឌនៃការឃុំឃាំងតាមការផ្តួចផ្តើម ទាំងដោយជនជាប់ចោទ និងការិយាល័យអយ្យការ និងការកំណត់ព្រំដែនថិរវេលា ដើម្បីដំណើរការទៅតាមអនុសាសន៍ដែលបានផ្តល់ក្នុងការព្យាបាលតាមបែបវេជ្ជសាស្ត្រ និងតាមរយៈថ្នាំកែរោគផ្សេងៗ (រួមទាំងការព្យាបាលដោយថ្នាំ*Donepezil* និងការព្យាបាលប្រើថ្នាំបែបអាជីព) មុននឹងមានការពិនិត្យឡើងវិញតាម*ការយល់ឃើញរបស់* អង្គជំនុំជម្រះសាលាដំបូង។

---

[41] សូមអាន គោលការណ៍២ នៃរបាយការណ៍របស់អ្នកជំនាញឯករាជ្យ ដើម្បីធ្វើបច្ចុប្បន្នភាពលើឈុតនៃគោលការណ៍ក្នុងការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព, គណកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, Diane Orentlicher, E/CN.4/2005/102/Add.1, ៨ កុម្ភៈ ២០០៥ ។

[42] *កំណត់សំគាល់ខាងដើម* លេខ៤១ ត្រង់គោលការណ៍ទី១៩ ។ សូមអានផងដែរ ចំណោទអំពីការផ្តន្ទាទោសនៃឧក្រិដ្ឋកម្មសង្គ្រាម និងជនទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ចំណោទអំពីការផ្តន្ទាទោស) ដែលបានអនុម័តនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៦៩, G.A. Res. 2583(XXIV), 24 U.N. GAOR Supp. (No. 30) ត្រង់ 58, U.N. Doc. A/RES/2583(XXIV) (1969); ចំណោទអំពីការផ្តន្ទាទោស ដែលបានអនុម័តនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧០, G.A. Res. 2712(XXV), 25 U.N. GAOR Supp. (No. 28) ត្រង់ 78-79, U.N. Doc. A/RES/2712(XXV) (1970); ចំណោទអំពីការផ្តន្ទាទោស ដែលបានអនុម័តនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧១, G.A. Res. 2840(XXVI), 26 U.N. GAOR Supp. (No. 29) ត្រង់ 88, U.N. Doc. A/RES/2840(XXVI) (1971) (កត់សម្គាល់ថា ការបដិសេធមិនសហការជាមួយយុត្តិធម៌នៅក្នុងកាលៈទេសដូច្នេះ គឺជាការផ្ទុយទៅនឹងនិយាមនៃច្បាប់អន្តរជាតិ); លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (លក្ខន្តិកៈទីក្រុងរ៉ូម), A/CONF.183/9, ១៧ កក្កដា ១៩៩៨, បានចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២, បុព្វកថា, យោបល់ទូទៅ លេខ ៣១, គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិចរិកលក្ខណៈនៃកាតព្វកិច្ចតាមផ្លូវច្បាប់ទូទៅដែលបានដាក់ទៅលើរដ្ឋជាភាគី ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, កថាខ័ណ្ឌទី១៥ និង១៨, U.N. Doc. CCPR/C/21/Rev.1/Add. ១៣ (២៦ ឧសភា ២០០៤) (កត់សម្គាល់អំពីភាពចាំបាច់នៃការរំលោភសិទ្ធិណាមួយត្រូវមានដំណោះស្រាយសមស្រប និង រួមទាំង ដំណោះស្រាយនៃ "ការនាំខ្លួនចារីដែលរំលោភសិទ្ធិមនុស្សមករកយុត្តិធម៌")។

២៧. អាស្រ័យហេតុនេះ ដូចបានស្នើឡើងនៅក្នុងបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលគួរទុកជាមោឃៈនូវការដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌ និងបង្គាប់ឲ្យជនជាប់ចោទទទួលការព្យាបាលបែបវេជ្ជសាស្ត្រ និងតាមរយៈថ្នាំកែរោគផ្សេងៗ ព្រមទាំងការពិនិត្យឡើងវិញលើលក្ខខណ្ឌរបស់ជនជាប់ចោទ នៅក្នុងរយៈពេលប្រាំមួយខែ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |